# អ្វីដែលត្រូវកើត ក៏កើតឡើង

ដោយពត៌មានពីអគ្គិភ័យ ដែលប្រុងនឹងមានឡើង ដូចដំរាយទាយនេះ លោកតា ជាង កេង នៅអធិការវត្តពោធិព្រឹក្ស នៅវត្តចាស់ ក៏បាននាំលោកតា សារ អ្នកនៅបំរើព្រះសង្ឃក្នុងវត្តនេះ ឱ្យទៅសួរពត៌មានពីអ្នកដឹកនាំចលនាយៀកមិញម្នាក់ឈ្មោះឡុង យួនកាត់ចិន ជាអតីតមេឃុំយួនហៅសាឡុង ផ្ទះនៅមាត់ព្រែក ពីរឿងផុតវស្សា ដើម្បីលោកនិមន្តទៅបិណ្ឌបាត កុំឱ្យធ្វើយ៉ាងនេះ ៗ លោកតា សារ មិនហ៊ាននៅផ្ទាល់ទេ តែបាននៅពឹងបងប្អូនយើងនៅផ្ទះជិតក្បែរវត្តទៅសាកសួរឱ្យ ៗ ដោយប្រទះនឹងព្រឹត្តិការណ៍បែបនេះបងប្អូនយើង ១៦ នាក់ ដែលមានឈ្មោះ ស៊ាង ជាម ក៏បានធ្វើដំណើរទៅរកយួន ឡុង ៗ គ្រាន់តែចូលដល់របងភូមិមេយៀកមិញ បាញ់ប្រាវ ៗ តែដោយកុសលមាន បងប្អូន

យើងក្រោបទាន់ហើយស្ទុះរត់ចូលទៅចាប់យួន ទាំងកំរោលផណ្ដើមយកបានតែកាំភ្លើង ។ ឯមេវៀតមិញ ផាយចេញតាមទ្វារក្រោយបាត់ទៅ ។

ក្រោយពីឧប្បត្តិហេតុទីមួយនេះកើតឡើង បងប្អូនយើងភាគច្រើនបានបន្ទោសគ្នាថា «នៅមិននៅ នាំគ្នាបុកសំបុកស្រាំងឲ្យផ្អើល» ។ នេះជាពាក្យមួយទៀតដែលបញ្ជាក់ឲ្យយើងឃើញថាយើងគ្មានបំណងណាមួយប្រទាំងផល់ចលនារបស់យួនវៀតមិញនោះទេ ហើយការពិត គឺយួនទេដែលប្រើអាវុធសម្លាប់យើង ពីព្រោះថ្ងៃដែលក្រុមខ្មែរ១៦ នាក់ចូលទៅរកជួបមេវៀតមិញនោះ យើងទៅដោយមានព្រះសង្ឃចង់ផ្សាបការពិត ដើម្បីសុំណ្ឋាមតរ កុំឲ្យគេ«បំផ្លាញផ្សារ» ។

ចំពោះគ្រោះកាចបែបនេះ អ្នកបន្ទោសគ្នា ក៏នេះតែបន្ទោសទៅ ប៉ុន្តែទាំងអស់គ្នា លែងចូលអ្វីទៀតហើយ ហើយក៏ចាប់ផ្ដើមប្រដាប់កាំបិត - ព្រៅគ្រប់គ្នាដោយចំហ ហើយចាត់គ្នាយាមគ្រប់ច្រកចូលភូមិ និងចាត់គ្នាឲ្យស្រង់គតិមានខ្លះដែលបានទទួលនូវគ្រប់ទីកន្លែង ។

នៅថ្ងៃទី ២០ ធ្នូ ១៩៤៥ មេវៀតមិញឈ្មោះ ឡុងដែលរត់ចោលកាំភ្លើងដួចពីរាបទាំងលើបាននាំគ្នាប្រហែល៩០នាក់មកពីកោះកុងដីម នៅមាត់ទន្លេមីចាញ់ ហៅទន្លេឯក្បូង បំណងការប្រហារបងប្អូនយើងនៅភូមិព្រែក

បាត ៗ ប៉ុន្តែគ្រាន់តែមួយម៉ោងក្រោយពីចុះពីទូកសម្ពៅ ឡើងដល់ដីលើគោកមក ក៏ត្រូវបងប្អូនយើងប្រមូលគ្នាដេញវាយប្រហារបាញ់ផ្គរលាន់នៅតាមវាលស្រែៗ យួនវៀតមិញដែលនៅសល់ពីស្លាប់ទាំងប៉ុន្មាន ក៏រត់ឡើងទូកចូលទៅរកជំរំរបស់វានៅឯកោះកុងមិនខ្ចោះអស់វិញទៅ ៗ នៅថ្ងៃនោះយើងមានទទួលខូចខាតតែបន្តិចបន្តួច ហើយថែមទាំងយកបានអាវុធបាញ់មួយដើមទៀតផង ក្រៅពីគ្រាប់បែកដី មីន ធ្នូ ស្នា មួយចំនួនធំ ៗ

បន្ទាប់ពីព្រឹត្តិការណ៍នៅភូមិព្រែកបាក់ដែលនៅចម្ងាយប្រហែល ៥ គ.ម ពីភូមិព្រែកគយមកបងប្អូនយើងបានផ្អាកកិច្ចការទាំងអស់ ហើយតែងប្រមូលផ្តុំគ្នាជាក្រុមតូច - ធំ តាមភូមិខាងនាក៏មាន នៅតាមព្រែកចូលផ្សារក៏មាន តាមវត្តអារាមក៏មាន ដើម្បីប្រជុំគ្នាការពារខ្លួន ឬធ្វើអន្តរាគមន៍ ៗ

រំលងថ្ងៃ ២៥ ធ្នូ ១៩៤៥ យួនវៀតមិញមួយក្រុមចំនួន ៣០ ក្លាយនាក់ប្រដាប់ដោយធ្នូ ស្នា កាំបិតហាន់ដើមចេកស្ន និងកាំភ្លើងប្រមាញ់ខ្លះ បានត្រូវបងប្អូនយើងដែលយាមនៅតាមផ្លូវចូលទៅផ្សារព្រែកគយព័ទ្ធជាប់បំរុងដកអាវុធ ៗ ប៉ុន្តែដោយមេយៀកមិញបានឱ្យដឹងថា គោលបំណងរបស់ក្រុមគេដែលចូលមកនេះគឺដើម្បីចង់ជួបថ្វាយបង្គំលោកតា ថាប់-ពេជ នៅអធិការវត្តពោធិព្រឹក្ស ដើម្បីសុំឱ្យលោកជួយ

ធ្វើការសំរុះសម្រួលកុំឲ្យខ្មែរ-យួន ឈ្លោះគ្នាតទៅទៀត ។ ដោយយើងឃើញថា នៅក្នុងផ្លូវចិត្តយួនទាំងនោះ មានព្រះសង្ឃទាំងមហាយានមួយអង្គ និមន្តជូនដំណើរមកជាមួយ ដែលយើងត្រូវតែទទួលស្គាល់ថា ជាសញ្ញាសន្តិភាពនោះ យើងក៏បានចាត់គ្នាឲ្យនិមន្តព្រះសង្ឃ ៣ អង្គនៅវត្តព្រហ្ម-វិសាល ហៅវត្ត កំពង់ឈើទាល គឺព្រះភិក្ខុ ថាច់ ចយ ព្រះភិក្ខុ លី ជា និងព្រះភិក្ខុ សុង ជា (១) ជាតំណាងព្រះសង្ឃនិងបងប្អូនយើងនៅព្រែកគយ ដើម្បីធ្វើការចរចា ជាមួយយួន ៗ ក្រោយពីយើង និងព្រះសង្ឃ បានធានាអះអាងដល់ក្រុមយួន ថាគោលដៅរបស់យើងគឺសេចក្ដីសុខ ខ្មែរ និង យួន ត្រូវទុកគ្នាជាបង-ប្អូនដែលរួចមុននោះមក និងមុនគេដកថយទៅកុងដីមវិញ យួនបានសុំនិមន្តព្រះសង្ឃទាំង ៣ អង្គនោះ និមន្តទៅជាមួយគេ ដើម្បីជាកិច្ចធានាដល់សេចក្ដីសុខរបស់គេនៅតាមផ្លូវ ៗ ដោយចង់ដឹងពីគោលបំណងពិតរបស់យៀកមិញ និងចង់ដឹងពីស្ថានការណ៍នៅកុងដីមជង និងតាមសេចក្ដីយល់ស្របពីលោកតា ថាច់ គេជ ព្រះសង្ឃទាំង ៣ អង្គក៏បានប្ដេជ្ញាព្រះទ័យ និមន្តជូនដំណើរយួនទៅវិញ តាម

---

*(១) គួរដំណឹងថាៈ អតីតព្រះភិក្ខុ សុង ជា បានចាកសិក្ខាបទហើយ សព្វថ្ងៃធ្វើជាយុទ្ធជននៅក្នុងកងឯកភាពមួយ ក្នុងកងទ័ពជាតិ ប៉ុន្តែមិនច្បាស់ទីកន្លែង ។*

សេចក្ដីសុំរបស់គេ ៗ សូមជំរាបថា ពេលក្រុមយួនដកថយទៅវិញភ្លាមក៏ស្រាប់តែឃើញពលរដ្ឋយួនទៅផ្សារព្រែកគយរាប់ម៉ឺននាក់បានដឹកកូន ជញ្ជូនចេញ ភៀសខ្លួនចេញពីផ្សារព្រែកគយទៅតាមទិសយួនដែរ ដែលជាហេតុមួយនាំឲ្យយើងដឹងថា យួនដែលចូលមក ៧០ ពួយនាក់ធ្វើជាមកចរចាជាមួយយើងនោះ ការពិតគឺគេយករំដោះជនជាតិយួនដទៃទៀតឲ្យថយចេញពីផ្សារព្រែកគយ ដើម្បីគេនាំយកមកវាយកម្ទេចខ្មែរយើងនៅថ្ងៃក្រោយប៉ុណ្ណោះ ។ រីឯការចរចារវាងគេនិងយើង ដូចជំរាបខាងលើ ក៏ និងវត្តមានព្រះសង្ឃយួនគ្រាន់តែជាលេសសំរាប់គេដោះដៃ ឲ្យផុតពីការឡោមព័ទ្ធរបស់ក្រុមអ្នកយាមខ្មែរយើង តែប៉ុណ្ណោះ ។

ពេលទៅដល់ភូមិធំ មេក្រុមយួនបានយកព្រះសង្ឃទាំង ៣ អង្គដែលនិមន្តទៅជាមួយ ទៅគង់ក្នុងរោងដាក់ដីត្រីមួយ ឃ្លាតឆ្ងាយពីផ្ទះយួនឯទៀត លុះមួយស្របក់ក្រោយមក ក៏ស្រាប់តែមានពលរដ្ឋយួនរាប់រយនាក់ មកនិយាយជេរប្រមាថដាក់ព្រះសង្ឃ ធ្វើឲ្យព្រះសង្ឃកើតក្ដីរន្ធត់ជាខ្លាំង ៗ បន្ទាប់មកទៀត មេទ័ពយួននៅទីនោះ បានយកកាំភ្លើងខ្លីមួយដើមមកបោះលើតុ រួចគេនិយាយទៅកាន់ព្រះសង្ឃដោយពាក្យបោះបញ្ជោះថា: «បើអ្នកណាហ៊ានធ្វើអីលោក លោកនេះបាញ់សំលាប់ បាញ់បំបែកក្បាលវាទៅ» ។ ប្រ

ហែលជាម៉ោង១២យប់ថ្ងៃនោះ មេយូខបាននាំព្រះសង្ឃទៅមើលឃ្លាំងអាវុធដែលឃើញមានកាំភ្លើងតូច-ធំ ដាក់តំរៀបគ្នាជាច្រើនជួរ ប៉ុន្តែមេយូខក៏បានហាមមិនឲ្យព្រះសង្ឃនិមន្តទៅជិតឃ្លាំងនោះទេ ដោយអាងថាក្រែងបណ្តាលឲ្យគ្រាប់បែកដែលស្តុកជាមួយនោះ ដែរផ្ទុះ អាចបណ្តាលឲ្យមានគ្រោះថ្នាក់ ។ ត្រង់នេះព្រះសង្ឃអាចឃើញច្បាស់ណាស់ ថាសុទ្ធតែកាំភ្លើងឈើស៊ីនតែទាំងអស់

លុះព្រឹកឡើង មេទ័ពយូខបានដោះលែងព្រះសង្ឃមួយអង្គឲ្យនិមន្តយកសំបុត្រ មកប្រគេនលោកតា ថាច់ តេជ ចៅអធិការវត្តព្រៃកគុយ សុំឲ្យលោកតាធានាអះអាងជាលាយលក្ខអក្សរ កុំឲ្យខ្មែររកបៀតបៀនយួនទៀត ។ ក្រោយពីលោកបានបំពេញតាមបំណងរបស់វាជាលើកទីមួយហើយ ថ្ងៃបន្ទាប់មក វាបានចាត់ព្រះសង្ឃមួយអង្គឲ្យនិមន្តយកសំបុត្រវាមកទៀត និយាយតែរឿងដដែល ។ លោកតា ថាច់ តេជ មិនទាន់ទាំងបានឆ្លើយតបសំបុត្រទីពីរនេះផង ក៏ស្រាប់តែឃើញព្រះសង្ឃអង្គទី ៣ និមន្តមកដល់ទៀត ដើម្បីរឿងដដែលទៀត ។ មកដល់ត្រង់នេះ យើងគ្មានត្រូវការអីចឹងចាញ់បោកយួនជាលើកទីពីរទៀតទេ ។ ដោយហេតុហ្នឹងហើយ បានជាយើងផ្តាច់ការទាក់ទងត្រឹមនេះសិន ដោយសារថាព្រះសង្ឃដែលជាប់ក្នុងកណ្តាប់ដៃវានោះ បានរួចមក

វិញហើយ ត្រូវការអ៊ីចិងចាត់ឲ្យស៊ីវិលទៅទៀត ។ គេ លែងព្រះសង្ឃ គឺព្រោះគេដឹងថាគេស្ថិតនៅត្រង់ចំណុចខ្សោយ ។